# Executive Summary | ខ្លឹមសារសង្ខេប

## *ទិដ្ឋភាពទូទៅ*

បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ ដែលបានចងសម្ពន្ធជាមួយគ្នាជាប្លុកក្នុងតំបន់មួយហៅថា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) មានភាពខុសគ្នាច្រើនលើទំហំភូមិសាស្ត្រ ប្រព័ន្ធគ្រប់គ្រង សេដ្ឋកិច្ច វប្បធម៌ និងក្រុមមនុស្សក្នុងសង្គមរបស់ពួកគេ។ ដូចគ្នានេះដែរ ប្រទេសនីមួយៗមានភាពខុសគ្នាលើការគោរពយ៉ាងខ្ជាប់ខ្ជួនតាមស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ និង ការការពារ (ឬការបដិសេធ) របស់ខ្លួនទៅលើសេរីភាព រួមទាំងសេរីភាពខាងសាសនាឬជំនឿជាសាកល។ ក្នុងខួបលើកទី 50 ឆ្នាំរបស់អាស៊ាន គណៈកម្មការសហរដ្ឋអាមេរិកទទួលបន្ទុកខាងសេរីភាពសាសនាអន្តរជាតិ (USCIRF) សូមបង្ហាញជូននូវរបាយការណ៍ដែលមានចំណងជើងថា *សិទ្ធិសម្រាប់គ្រប់គ្នា៖ សេរីភាពខាងសាសនាឬជំនឿនៅអាស៊ាន*។ របាយការណ៍នេះចងក្រងអំពីវិធីសាស្ត្ររបស់អាស៊ាននិងរដ្ឋសមាជិកចំពោះសិទ្ធិជាមូលដ្ឋាននេះ, គូសបញ្ជាក់អំពីការប្រឈមនានាពាក់ព័ន្ធនឹងសេរីភាពខាងសាសនាក្នុងតំបន់នេះរហូតដល់ហួសពីព្រំដែនប្រទេស ព្រមទាំងសង្កត់ធ្ងន់លើភាពសំខាន់ជាយុទ្ធសាស្ត្រនៃការចូលរួមពាក់ព័ន្ធដ៏ខ្លាំងក្លារបស់សហរដ្ឋអាមេរិកលើបញ្ហាទាំងនេះ ជាមួយអាស៊ានជារួម និង ជាមួយរដ្ឋសមាជិកនីមួយៗទាំង 10៖ ប្រ៊ុយណេ, ភូមា, កម្ពុជា, ឥណ្ឌូនេស៊ី, ឡាវ, ម៉ាឡេស៊ី, ហ្វីលីពីន, សិង្ហបុរី, ថៃ និង វៀតណាម។

វិធីសាស្ត្ររបស់អាស៊ានចំពោះសិទ្ធិមនុស្ស ជាញឹកញាប់ បានធ្លាក់ចុះអន់ថយតាមរយៈផលប្រយោជន៍ប្រជែងគ្នាពីរ៖ ចំណង់របស់រដ្ឋសមាជិកក្នុងការធ្វើសមាហរណកម្មជាប្លុកមួយ និង ការសង្ឃឹមក្នុងទីជម្រៅរបស់ពួកគេទៅលើឯករាជ្យភាពនិងភាពគ្មានការជ្រៀតជ្រែកក្នុងកិច្ចការរបស់សមាជិកមួយទៀត។ ក្នុងសហគមន៍ដែលពឹងពាក់គ្នាទៅវិញទៅមក ភ្ជាប់ទំនាក់ទំនងគ្នាទៅវិញទៅមកច្រើនឡើងៗ ដូចជាអាស៊ាន វាពិតជាសំខាន់ណាស់ដែលរដ្ឋាភិបាលនិងសង្គមទទួលស្គាល់ (ទាំងនៅក្នុងប្រទេស និង ឆ្លងព្រំដែនរបស់ពួកគេ) នៅពេលមានការរំលោភបំពានលើសិទ្ធិមានសេរីភាពខាងសាសនាឬជំនឿ ហើយត្រូវចាត់វិធានការដើម្បីការពាររូបវន្តបុគ្គលនិងក្រុមដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន។

សហរដ្ឋអាមេរិក ដែលបច្ចុប្បន្នកំពុងបន្តចងមេត្រីភាពក្នុងខួបលើកទី 40 ឆ្នាំរបស់ខ្លួនជាមួយអាស៊ាន បានដាក់ទម្ងន់និងប្រើឥទ្ធិពលដ៏សំខាន់ក្នុងតំបន់នេះ និង ជាមួយរដ្ឋសមាជិកនីមួយៗ។ សហរដ្ឋអាមេរិកត្រូវតែលើកទឹកចិត្តរដ្ឋសមាជិករបស់អាស៊ានឲ្យសម្រេចបាននូវគោលបំណងផ្តល់ភាពចម្រើនរុងរឿងដល់ប្រជាជនផ្ទាល់ខ្លួនរបស់ពួកគេ ព្រមទាំងបំពេញតាមគោលការណ៍ស្នូលដែលប្រទេសទាំងអស់យល់ព្រម នៅពេលចូលរួមក្នុងអង្គការសហប្រជាជាតិ និង នៅពេលក្លាយជាភាគីមួយនៃលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ។

## *អាស៊ាន សិទ្ធិមនុស្ស និងសេរីភាពខាងសាសនាឬជំនឿ*

អាស៊ាន និង រដ្ឋសមាជិកនីមួយៗមានកំណត់ត្រាមិនសូវត្រូវគ្នាឡើយអំពីការការពារនិងការលើកកម្ពស់សិទ្ធិមនុស្ស ហើយកាន់តែមិនសូវត្រូវគ្នាច្រើនទៀតពាក់ព័ន្ធនឹងសេរីភាពខាងសាសនាឬជំនឿ។ ជាញឹកញាប់ ប្រទេសនៅអាស៊ានមានកង្វះខាតសន្តិវៈនិងឆន្ទៈខ្លាំងក្នុងការធ្វើសកម្មភាពតបតនឹងការរំលោភបំពានធ្ងន់ធ្ងរនៅក្នុងព្រំដែនផ្ទាល់ខ្លួនរបស់ពួកគេ និង ក្នុងចំណោមរដ្ឋសមាជិកផ្សេងទៀតនៃប្លុកនេះ។ ក្នុងឆ្នាំ 2009 អាស៊ានបានបង្កើត គណៈកម្មាការអន្តររដ្ឋាភិបាលទទួលបន្ទុកខាងសិទ្ធិមនុស្ស (AICHR) ហើយក្នុងឆ្នាំ 2012 ខ្លួនបានអនុម័ត សេចក្តីប្រកាសអំពីសិទ្ធិមនុស្សនៅអាស៊ាន (AHRD)។ អ្នករិះគន់បានចោទសួរអំពីភាពស័ក្តិសិទ្ធិរបស់ AICHR ក្នុងនាម

ជាស្ថាប័នទទួលបន្ទុកខាងសិទ្ធិមនុស្ស និង AHRD ជាលិខិតុបករណ៍សិទ្ធិមនុស្ស។ សហគមន៍អន្តរជាតិត្រូវអំពាវនាវឲ្យរដ្ឋសមាជិកគោរពតាមស្តង់ដាខ្ពស់ជាងនេះដែលបានរួមបញ្ចូលទៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដូចជា សន្ធិសញ្ញាអន្តរជាតិអំពីសិទ្ធិពលរដ្ឋនិងនយោបាយ (ICCPR)។

គំហើញសំខាន់ៗអំពីសេរីភាពខាងសាសនាឬជំនឿក្នុងរដ្ឋសមាជិកទាំង 10 រួមមាន៖

- **ប្រ៊ុយណេ៖** អត្តសញ្ញាណរបស់រដ្ឋនិងរូបរាងសាធារណៈជាឥស្លាមក្រោមការគ្រប់គ្រងរបស់ស្តេចស៊ុលតង់ ពេលខ្លះបង្កឲ្យមានការចោទសួរលើសេរីភាពខាងសាសនារបស់ជនមិនមែនមូស្លីម និង អ្នកតាំងទីលំនៅជាមូស្លីមហេតេរ៉ូដុក ដែលសហគមន៍របស់ពួកគេអាចត្រូវបានហាមប្រាមឬគ្រប់គ្រងដោយ Shari’ah ថ្វីបើជាសម្ពន្ធជាមួយពួកគេក៏ដោយ។
- **ភូមា៖** ថ្វីបើឆ្នាំ 2016 បានកត់សម្គាល់នូវការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រប្រកបដោយសន្តិភាពនៃរដ្ឋាភិបាលភូមាក៏ដោយ និទណ្ឌភាពទាំងស្រុងចំពោះការរំលោភបំពានដែលពួកយោធានិងសកម្មជនក្រៅរដ្ឋខ្លះបានធ្វើ ព្រមទាំងវិបត្តិមនុស្សធម៌ដ៏ជ្រាលជ្រៅសម្រាប់អ្នកផ្លាស់ទីកន្លែង បន្តជំរុញឲ្យមានការប្រព្រឹត្តិឃោឃៅលើក្រុមសាសនានិងក្រុមជនជាតិភាគតិច។
- **កម្ពុជា៖** កម្ពុជាមានការប្រឈមផ្ទៃក្នុងតិចតួចប៉ុណ្ណោះជាមួយនឹងសេរីភាពខាងសាសនាឬជំនឿ ប៉ុន្តែអាចធ្វើបានលើសពីនេះដើម្បីគាំពារនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្ស ជាពិសេសក្រោមអនុសញ្ញាស្តីពីជនភៀសខ្លួន។
- **ឥណ្ឌូនេស៊ី៖** រដ្ឋាភិបាលឥណ្ឌូនេស៊ីជារឿយៗតែងធ្វើអន្តរាគមន៍ នៅពេលមានការរំលោភបំពានលើសេរីភាពខាងសាសនាកើតឡើង ជាពិសេស បើការបំពានទាំងនោះពាក់ព័ន្ធនឹងអំពើហិង្សា។ ទោះជាយ៉ាងនេះក្តី ពួកមិនមែនមូស្លីម និង ពួកមូស្លីមមិនមែនកាន់និកាយស៊ុននី ត្រូវស៊ូទ្រាំនឹងភាពលំបាកជាបន្តបន្ទាប់ក្នុងការទទួលនូវការអនុញ្ញាតជាផ្លូវការឲ្យសាងសង់ទីសក្ការៈបូជា, ជួបប្រទះនូវការបំផ្លិតបំផ្លាញទីសក្ការៈបូជា ព្រមទាំងទទួលរងការរើសអើង និង ពេលខ្លះ ការតវ៉ាដោយហិង្សា ដែលបង្អាក់រំខានដល់លទ្ធភាពរបស់ពួកគេក្នុងការគោរពប្រតិបត្តិជំនឿរបស់ពួកគេ។
- **ឡាវ៖** នៅតំបន់ខ្លះនៃប្រទេសឡាវ អាជ្ញាធរក្នុងស្រុកបៀតបៀននិងរើសអើងប្រឆាំងនឹងពួកជនជាតិភាគតិចនិងក្រុមនិកាយសាសនាភាគតិច ព្រមទាំងដាក់ចេញនូវបទបញ្ញត្តិគ្រប់គ្រងនិងបទបញ្ជាដ៏សន្ធឹកសន្ធាប់របស់រដ្ឋាភិបាលដែលរារាំងដល់សេរីភាពខាងសាសនាឬជំនឿ។
- **ម៉ាឡេស៊ី៖** ប្រព័ន្ធរដ្ឋាភិបាលការពារខ្លួនរបស់ម៉ាឡេស៊ីផ្តល់គុណប្រយោជន៍ដល់គណបក្សកាន់អំណាច និង ប្រជាជនម៉ាឡេដែលជាពួកមូស្លីមស៊ុននី ដោយទុកឲ្យជនជាតិភាគតិចនិងក្រុមនិកាយសាសនាភាគតិចទទួលរងផលប៉ះពាល់ ដែលជាញឹកញាប់ឃើញមានតាមរយៈការបំបែកដោយផ្ទាល់ពីរដ្ឋាភិបាលលើសកម្មភាពសាសនា ការបញ្ចេញមតិ ឬការខ្វែងយោបល់។
- **ហ្វីលីពីន៖** ដោយមានឥទ្ធិពលដ៏ខ្លាំងពីព្រះវិហារកាតូលិក ព្រមជាមួយនឹងតម្រូវការនានារបស់ក្រុមសាសនាផ្សេងទៀត ហ្វីលីពីនព្យាយាមរកដំណោះស្រាយជាមួយនឹងការបំបែកចេញពីគ្នារវាងព្រះវិហារនិងរដ្ឋ ហើយក៏មានអំពើហិង្សាដែលបន្តគ្របសង្កត់លើទំនាក់ទំនងជាមួយពួកមូស្លីមលើកោះ Mindanao ផងដែរ។
- **សិង្ហបុរី៖** ប្រវត្តិនៃអំពើហិង្សាអន្តរសហគមន៍របស់សិង្ហបុរីជូនដំណឹងអំពីគោលនយោបាយបច្ចុប្បន្នរបស់ខ្លួន ដែលផ្តល់អាទិភាពចំពោះភាពសុខដុមរវាងសាសនាចម្បងៗរបស់ប្រទេស ដែលពេលខ្លះមិនផ្តល់តម្លៃដល់សេរីភាពនៃការបញ្ចេញមតិ និង សិទ្ធិរបស់សហគមន៍សាសនាតូចៗឡើយ។
- **ថៃ៖** ភាពចម្បងនៃពុទ្ធសាសនាគឺជាបញ្ហាមិនដាច់ស្រេចបំផុតចំពោះសេរីភាពខាងសាសនាឬជំនឿក្នុងខេត្តភាគខាងត្បូងដែលសម្បូរដោយពួកមូស្លីមម៉ាឡេជាច្រើន ដែលនៅកន្លែងនោះ ភាពតានតឹងជាបន្តបន្ទាប់រវាងពុទ្ធសាសនិក-មូស្លីម នាំឲ្យមានការកើនឡើងនៃជាតិនិយមផ្អែកលើសាសនាទូទាំងប្រទេស។
- **វៀតណាម៖** វៀតណាមបាននិងកំពុងកែលម្អស្ថានភាពនៃសេរីភាពខាងសាសនា ប៉ុន្តែអំពើហិង្សាធ្ងន់ធ្ងរនៅតែបន្តមានជាពិសេសទៅលើសហគមន៍ជនជាតិភាគតិចក្នុងតំបន់ជនបទនៃខេត្តខ្លះ។

## *ការប្រឈម*

រដ្ឋសមាជិកទាំង 10 ធ្លាប់ជួបប្រទះនូវការប្រឈមទូទៅនិងការប្រឈមដែលធ្លាប់បានឆ្លងកាត់មួយចំនួន ដែលគួសបញ្ជាក់ថាតើអំពើហិង្សានៃសេរីភាពខាងសាសនាឬជំនឿ កើតឡើងឆ្លងព្រំដែន និង នៅក្នុងបរិការណ៍នៃនិន្នាការក្នុងតំបន់ធំនិងតំបន់ពាក់ព័ន្ធដូចម្តេច។ អាស៊ានគួរទទួលស្គាល់និងធ្វើការដើម្បីថ្លែងពីបញ្ហាខាងក្រោម៖ ចន្លោះប្រហោងនៃការការពារជនភៀសខ្លួន អ្នកស្នើសុំសិទ្ធិជ្រកកោន បុគ្គលដែលត្រូវបានជួញដូរ និងអ្នកដែលបានផ្លាស់ទីលំនៅក្នុងប្រទេស; ការប្រើប្រាស់ច្បាប់ប្រឆាំងនឹងភាពជ្រុលនិយម និង ប្រឆាំងនឹងភាវរនិយម ជាមធ្យោបាយដើម្បីកម្រិតសកម្មភាពស្របច្បាប់របស់សហាគមន៍សាសនា បង្ក្រាបភាពខ្វែងគំនិតដោយសន្តិភាព និងចាប់មនុស្សដាក់គុក; ការប្រើប្រាស់មនោសញ្ចេតនាជាតិសាសន៍របស់បុគ្គលនិងក្រុមដែលប្រើប្រាស់សាសនា ដើម្បីបង្កអន្តរាយដល់ក្រុមជនជាតិភាគតិចនិងក្រុមនិកាយសាសនាភាគតិចផ្សេងទៀត; ការចាប់ខ្លួន ការឃុំឃាំង និងការដាក់គុក ដោយផ្អែកលើជំនឿសាសនាការប្រតិបត្តិ ឬសកម្មភាពនានា; ព្រមទាំងការមាននិងការអនុវត្តច្បាប់បណ្តាសាដែលត្រូវបានប្រើដើម្បីញុះញង់ឬបំផុសឲ្យមានអំពើហិង្សា ដែលជាទូទៅដោយសមាជិករបស់ក្រុមនិកាយសាសនាភាគច្រើន ប្រឆាំងនឹងក្រុមមកពីសហាគមន៍និកាយសាសនាភាគតិច។

## *គោលការណ៍គ្មានការជ្រៀតជ្រែករបស់អាស៊ាន*

ជាធម្មតា រដ្ឋសមាជិកអាស៊ានអំពាវនាវឲ្យប្រើគោលការណ៍គ្មានការជ្រៀតជ្រែក (គោលការណ៍អធិបតេយ្យភាពជាតិ បូរណភាពដែនដី និងឯករាជ្យភាព) ប៉ុន្តែម្តងម្កាលបានដាក់គោលការណ៍នេះនៅមួយឡែក នៅពេលវាមានប្រយោជន៍ដល់ពួកគេ។ ក្នុងពេលដែលគេដឹងថា ប្រទេសអាស៊ានការពារប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេជាមុននិងជំបូងបំផុត រដ្ឋនីមួយៗត្រូវមានការទទួលខុសត្រូវទូលំទូលាយក្នុងការធ្វើសកម្មភាពដោយសុខដុមជាមួយសហាគមន៍នៃបណ្តាប្រទេសនានា ជាពិសេសនៅពេលមានបញ្ហាសិទ្ធិមនុស្ស រួមទាំងសេរីភាពខាងសាសនាឬជំនឿ កើតឡើងឆ្លងព្រំដែនប្រទេស។

## *ទំនាក់ទំនងរវាងសហរដ្ឋអាមេរិក-អាស៊ាន*

ក្នុងអំឡុងខួបលើកទី 50 ឆ្នាំ របស់អាស៊ាន និង បន្ទាប់ពីមានទំនាក់ទំនង 40 ឆ្នាំ រវាងសហរដ្ឋអាមេរិក-អាស៊ាន សហរដ្ឋអាមេរិកគួរលើកកម្ពស់ចំណាប់អារម្មណ៍និងឥទ្ធិពលរបស់ខ្លួនក្នុងតំបន់នេះ ដើម្បីបង្ខំឲ្យរដ្ឋសមាជិកគោរពស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ។ ទោះបីជារដ្ឋសមាជិកអាស៊ានខ្លះបើកចំហចំពោះការចូលរួមពាក់ព័ន្ធរបស់សហរដ្ឋអាមេរិកលើបញ្ហាសិទ្ធិមនុស្សជាងរដ្ឋផ្សេងទៀតក្តី ការបង្ខំដ៏ខ្លាំងក្លានិងជាប់លាប់ពីសហរដ្ឋអាមេរិក រួមទាំងការពង្រឹងឡើងវិញជាវិជ្ជមាននៅពេលមានការធានា នឹងបញ្ជូនសញ្ញាដ៏ច្បាស់លាស់អំពីអាទិភាពរបស់សហរដ្ឋអាមេរិកនៅក្នុងតំបន់នេះ។

## *សន្និដ្ឋាន*

អាស៊ាននិងរដ្ឋសមាជិកនីមួយៗត្រូវតែយល់ដឹងថា សហាគមន៍ប្រជាជាតិសាកលស្ថិតនៅបិតថេរ នៅពេលគ្រប់គ្នាគោរពបទបញ្ជាអន្តរជាតិដោយមានមូលដ្ឋានលើការគ្រប់គ្រង ដែលរួមបញ្ចូលនូវការទទួលខុសត្រូវក្នុងការគោរពសេរីភាពខាងសាសនាឬជំនឿ ព្រមទាំងសិទ្ធិមនុស្សពាក់ព័ន្ធ។ នេះមានន័យថា អាស៊ាន និង រដ្ឋសមាជិកត្រូវចាត់វិធានការដើម្បី៖

- គោរពយ៉ាងខ្ជាប់ខ្ជួនតាមលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ;
- ស្វាគមន៍ទស្សនកិច្ចរបស់អ្នកឃ្លាំមើលសិទ្ធមនុស្សអន្តរជាតិ;
- ធានាឲ្យបានថា បុគ្គលិកជំនួយ អ្នកសារព័ត៌មានឯករាជ្យ និងភាគីអន្តរជាតិពាក់ព័ន្ធផ្សេងទៀត អាចទៅដល់កន្លែងរបស់ប្រជាជនដែលងាយទទួលរងគ្រោះ និង តំបន់មានជម្លោះ ដោយគ្មានកំហិត។

- លុបចោលនូវច្បាប់បណ្តាសា និង ច្បាប់ពាក់ព័ន្ធ;
- ដោះលែងអ្នកទោសមនសិការ; និង
- ពង្រឹងទំនាក់ទំនងអន្តរជំនឿ។



# Cambodia | កម្ពុជា

**ឈ្មោះពេញ៖** ព្រះរាជាណាចក្រកម្ពុជា
**រដ្ឋាភិបាល៖** រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ
**ប្រជាជន៖** 15,957,223
**សាសនា/ជំនឿដែលទទួលស្គាល់ដោយរដ្ឋាភិបាល៖** ព្រះពុទ្ធសាសនា (សាសនាផ្លូវការរបស់រដ្ឋ); ក្រុមនិកាយសាសនាផ្សេងទៀតដែលចុះបញ្ជី
**ប្រជាសាស្ត្រតាមសាសនា៖**

- ពុទ្ធសាសនិក៖ 96.9%
- មូស្លីម៖ 1.9%
- គ្រិស្តបរិស័ទ៖ 0.4%
- ផ្សេងទៀត៖ 0.8%

**គំហើញសំខាន់ៗ៖** កម្ពុជាមានការប្រឈមផ្ទៃក្នុងតិចតួចប៉ុណ្ណោះជាមួយនឹងសេរីភាពខាងសាសនាឬជំនឿ ប៉ុន្តែអាចធ្វើបានលើសពីនេះ ដើម្បីគាំពារនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្ស ជាពិសេសក្រោមអនុសញ្ញាស្តីពីជនភៀសខ្លួន។

កម្ពុជាបច្ចុប្បន្ន ដែលស្ថិតក្រោមការដឹកនាំរបស់ព្រះមហាក្សត្រ និង ត្រូវបានគ្រប់គ្រងអំណាចដោយរដ្ឋសភា បានរស់ឡើងវិញក្រោយពីការកសាងប្រទេសឡើងវិញ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ជារបបកុម្មុយនីស្តម៉ាកស៊ីស្តដ៏ឃោរឃៅ ដែលបានឡើងកាន់អំណោចក្នុងអំឡុងសង្គ្រាមស៊ីវីល ៥ ឆ្នាំ។ ក្រោមការគ្រប់គ្រងរបស់មេដឹកនាំផ្តាច់ការ ប៉ុល ពត របបខ្មែរក្រហមបានបំបិទលែងឲ្យមានការចាយប្រាក់ ទ្រព្យសម្បត្តិឯកជន និងសាសនា ព្រមទាំងបានធ្វើឲ្យប្រជាជនស្លាប់ជិតមួយភាគបួននៃប្រជាជនសរុប តាមរយៈការប្រហារជីវិត ជំងឺ និងភាពអត់ឃ្លាន។ របបនេះបានផ្តោតគោលដៅជាពិសេសលើក្រុមជនជាតិភាគតិចនិងក្រុមនិកាយសាសនាភាគតិចមួយចំនួន រួមមានជនជាតិភាគតិចវៀតណាម ជនជាតិភាគតិចចិន និងជនជាតិចាមមូស្លីមជាច្រើន។ សាលាក្តីខ្មែរក្រហមដែលជាសាលាក្តីកូនកាត់បន្តពិនិត្យលើការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍ដែលបានធ្វើលើជនជាតិចាម។

សព្វថ្ងៃ ប្រជាជនកម្ពុជាជាង 96 ភាគរយកាន់ព្រះពុទ្ធសាសនាថេរវាទ និង ប្រមាណ 2 ភាគរយគឺជាពួកមូស្លីម ហើយប្រជាជនមួយចំនួនតូចទៀតគោរពសាសនាបាហៃ ជីហ្វ កៅដាយ និងគ្រិស្ត។ ជនជាតិមូស្លីមនៅក្នុងប្រទេសភាគច្រើនគឺកាន់និកាយស្យាហ្វី ស៊ុននី (Shafi'i Sunnis) ប៉ុន្តែក៏មានចំនួនតិចតួចដែរ ដែលគោរពសាឡាហ្វីស (Salafis), អាហ៍ម៉ាឌីស (Ahmadis) និង អន្តោគ្រាម អ៊ីម៉ាន់-សាន (Iman-San)។ រដ្ឋធម្មនុញ្ញកម្ពុជាបានលើកកម្ពស់ភាពស្មើគ្នានៅចំពោះមុខច្បាប់ សម្រាប់ពលរដ្ឋទាំងអស់ ដោយមិនគិតពីប្រភេទ រួមទាំងពូជសាសន៍ ភេទ ជំនឿសាសនា និងដើមកំណើតជាតិ។ ដូចគ្នានេះដែរ រដ្ឋធម្មនុញ្ញបានធានានូវសេរីភាពនៃការបញ្ចេញមតិ និង សេរីភាពខាងជំនឿសាសនា ប៉ុន្តែសេរីភាពទាំងពីរនៅមានកម្រិត ដោយសារសេរីភាពទាំងនេះត្រូវបានហាមប្រាមមិនឲ្យដល់ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនិងសន្តិសុខជាតិឡើយ។ លើសពីនេះ ព្រះពុទ្ធសាសនាត្រូវបានកត់សម្គាល់ថាជាសាសនារបស់រដ្ឋ ក្រោមបាវចនាជាតិគឺ "ជាតិ សាសនា ព្រះមហាក្សត្រ" ហើយរដ្ឋធម្មនុញ្ញបានចែងអំពីការបង្កើតសាលាបាលីនិងវិទ្យាស្ថានពុទ្ធសាសនិករបស់រដ្ឋ។ ក្រុមនិកាយសាសនាទាំងអស់ រួមទាំងស្ថាប័នពុទ្ធសាសនា ត្រូវបានតម្រូវដោយច្បាប់ឲ្យចុះបញ្ជីជាមួយក្រសួងធម្មការនិងសាសនា, ផ្តល់ជូនរដ្ឋាភិបាល

នូវព័ត៌មាននានា រួមទាំងប្រភពមូលនិធិ និង ជីវប្រវត្តិរបស់អ្នកដឹកនាំ។ ការចុះបញ្ជីក៏តម្រូវឲ្យមានការយល់ព្រមអត់ធ្មត់ ដោយមិនត្រូវមើលងាយក្រុមសាសនាផ្សេងទៀត បង្កើតជាទំនាស់ ឬបង្កអសន្តិសុខដល់សង្គមដែរ។

សព្វថ្ងៃ ជនជាតិភាគតិចចាម ដែលប្រតិបត្តិទម្រង់អន្តោគ្រាមនៃសាសនាឥស្លាមរួមគ្នានិងបានផ្តុំគ្នារស់នៅជុំវិញទន្លេមេគង្គ បឹងទន្លេសាប និងតាមតំបន់ឆ្នេរសមុទ្រក្នុងខេត្តកំពត បានធ្វើសមាហរណកម្មទៅជាសង្គមដ៏ធំមួយ ប៉ុន្តែនៅតែបន្តជួបប្រទះការប្រឈមនឹងឱកាសទទួលការអប់រំនិងឱកាសសេដ្ឋកិច្ច។ ពួកគេត្រូវបានសមាជិកខ្លះនៃសហគមន៍ផ្សេងទៀតយល់ថាជាអ្នកប្រតិបត្តិ "មន្តអាគមងងឹត" ដែលធ្វើឲ្យម្តងម្កាលទទួលរងនូវការមុំគ្នាវាយប្រហារ ហើយជាញឹកញាប់ ប៉ូលីសក្នុងស្រុកតែងតែខ្វះសមត្ថភាពក្នុងការបង្ការ។ រដ្ឋាភិបាលបានចាត់វិធានការដើម្បីថ្លែងអំពីវិសមភាពនិងភាពតានតឹងក្នុងសង្គមទាំងនេះ ហើយអ្វីដែលគួរឲ្យកត់សម្គាល់នោះគឺតាមរយៈសំណុំនៃអនុក្រឹតក្នុងខែមិថុនា ឆ្នាំ 2015។ ក្នុងអនុក្រឹតដំបូង ក្រសួងអប់រំបានប្រកាសពីបំណងរបស់ខ្លួនក្នុងការជួលគ្រូបង្រៀនជាជនជាតិចាម 1500 នាក់ ហើយអនុក្រឹតទីពីរបានអនុញ្ញាតឲ្យជនជាតិចាមមូស្លីមស្លៀកសម្លៀកបំពាក់សាសនាក្នុងរូបថតផ្លូវការ។ ទោះជាយ៉ាងនេះក្តី ដោយគិតពិចារណាលើការចោទប្រកាន់អំពីទំនាក់ទំនងរវាងពួកមូស្លីមកម្ពុជានិងអំពើហិង្សារបស់ពួកឥស្លាមជ្រុលនិយម រដ្ឋាភិបាលកម្ពុជាបានត្រួតពិនិត្យយ៉ាងជិតដល់លើការផ្តល់មូលនិធិដល់សាលារៀននិងស្ថាប័នឥស្លាម ជាពិសេសស្ថាប័នដែលពាក់ព័ន្ធជាមួយនឹងក្រុមអភិរក្សខ្លាំងដូចជាពួកសាឡាហ្វីសដែលមានសម្ពន្ធនៅឈូងសមុទ្រពែក្ស (Gulf-affiliated Salafis) ឬ ចលនា Tablighi Jamaat ដែលត្រូវបានជំរុញដោយថ្នាក់ដឹកនាំនៅអាស៊ីខាងត្បូងនិងម៉ាឡេស៊ី។

កម្ពុជាបានទទួលរងការរិះគន់ពីអន្តរជាតិចំពោះការឆ្លើយតបរបស់ខ្លួនលើពួកស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ា ដែលឆ្លងមកពីប្រទេសវៀតណាម។ ក្នុងប្រទេសកំណើតរបស់គេ ក្រុមជនជាតិភាគតិចប្រូតេស្តង់ដ៏ធំមួយនេះ ត្រូវបានហាមឃាត់ដោយរដ្ឋាភិបាលមិនឲ្យគោរពប្រតិបត្តិជំនឿសាសនារបស់ខ្លួន, សមាជិកជាច្រើនរូបជួបប្រទះភាពក្រីក្រដោយសារការដណ្តើមយកដីធ្លី ហើយគ្រូគង្វាលបានទទួលការបៀតបៀនឬការដាក់ទណ្ឌកម្ម។ ក្នុងនាមជារដ្ឋហត្ថលេខីនៃអនុសញ្ញាស្តីពីជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាគោរពតាមគោលការណ៍មិនប្រគល់ជនភៀសខ្លួនដែលប្រឈមនឹងការគំរាមកំហែងធ្ងន់ធ្ងរដល់ជីវិតឬសេរីភាពរបស់ពួកគេនៅក្នុងប្រទេសដើមកំណើតរបស់ពួកគេ ទៅប្រទេសកំណើតរបស់ពួកគេវិញឡើយ។ ទោះជាយ៉ាងនេះក្តី យោងតាមឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកខាងជនភៀសខ្លួន (UNHCR) រដ្ឋាភិបាលកម្ពុជាបានប្រគល់ជនភៀសខ្លួនម៉ុងតាញ៉ាដែលស្នើសុំសិទ្ធិជ្រកកោនយ៉ាងតិច 100 នាក់ ទៅប្រទេសវៀតណាមវិញ ចាប់តាំងពីខែកក្កដា ឆ្នាំ 2015 ដោយមិនកំណត់អំពីស្ថានភាពនៃការភៀសខ្លួនរបស់ពួកគេ។ ក្នុងខែមេសា ឆ្នាំ 2015 រដ្ឋាភិបាលបានបញ្ជូនទាហាន 1000 នាក់ ទៅព្រំដែនកម្ពុជាវៀតណាម ដើម្បីរារាំងមិនឲ្យពួកម៉ុងតាញ៉ាផ្សេងទៀតឆ្លងចូលក្នុងប្រទេសកម្ពុជា។ អ្នកនាំពាក្យរាជរដ្ឋាភិបាលបានបញ្ជាក់ថា ការយល់ព្រមទទួលជនភៀសខ្លួនឲ្យមកតាំងទីលំនៅជាថ្មីក្នុងប្រទេសកម្ពុជា នឹងខុសពីរដ្ឋធម្មនុញ្ញ ដោយសាររដ្ឋធម្មនុញ្ញបានចែងអំពីអព្យាក្រឹតភាពរបស់ជាតិ។ រហូតដល់ខែមករា ឆ្នាំ 2016 ពួកម៉ុងតាញ៉ាតិចតួចណាស់ដែលបានទទួលការអនុញ្ញាតឲ្យចុះបញ្ជីស្នើសុំសិទ្ធិជ្រកកោន ដែលចាប់តាំងពីពេលនោះមក រដ្ឋាភិបាលកម្ពុជាបានអះអាងថា បានវាយតម្លៃបណ្តឹងស្នើសុំទាំងអស់ដែលបានដាក់ឯកសារ ប៉ុន្តែបានបដិសេធសំណុំរឿងស្ទើតែទាំងអស់ ជាហេតុធ្វើឲ្យអ្នកស្នើសុំសិទ្ធិជ្រកកោនម៉ុងតាញ៉ាខ្លះរត់ភៀសខ្លួនទៅប្រទេសថៃ ដោយភ័យខ្លាចការបញ្ជូនទៅមាតុភូមិវិញ។

ក្នុងខែកញ្ញា ឆ្នាំ 2017 រដ្ឋាភិបាលអូស្ត្រាលីបានធ្វើកិច្ចព្រមព្រៀងបញ្ជូនជនភៀសខ្លួនមកតាំងទីលំនៅជាថ្មី ជាមួយរដ្ឋាភិបាលកម្ពុជា បង្កឲ្យមានភាពចម្រូងចម្រាសគ្នាជាមួយករណីពីមុន។ បើទោះបីជាគេមិនដឹងព័ត៌មានលម្អិតពាក់ព័ន្ធនឹងប្រាក់កាសក៏ដោយ របាយការណ៍ជាច្រើនបានលើកឡើងថាមានកិច្ចព្រមព្រៀងដែលរួមបញ្ចូលប្រាក់ 40 លានដុល្លារអូស្ត្រាលី ក្នុងជំនួយអភិវឌ្ឍន៍បន្ថែម និង 15 លានដុល្លារអូស្ត្រាលី (ជាង 30 លានដុល្លារអាមេរិក និង ជាង 11 លានដុល្លារអាមេរិក) សម្រាប់សោហ៊ុយនៃការតាំងទីលំនៅជាថ្មីរបស់ជនភៀសខ្លួនទៅអូស្ត្រាលីដែលត្រូវតាំងទីលំនៅជាថ្មីនៅកម្ពុជា ដែលពីមុន ពួកគេត្រូវបានដាក់ឲ្យរស់នៅក្នុងមជ្ឈមណ្ឌលឃុំឃាំងលើកោះណូរុ។ ដំណឹងអំពីការរៀបចំនេះបានទទួលប្រតិកម្មអវិជ្ជមានដ៏ខ្លាំងក្លាពីចំណោមអ្នកដែលកំពុងស្នើសុំសិទ្ធិជ្រកកោន។ រដ្ឋាភិបាលអូស្ត្រាលីបានបោះខិត្តបណ្ណផ្សព្វផ្សាយក្នុងជំរុំនៅលើកោះណូរុ ដោយពណ៌នាពីប្រទេសកម្ពុជាថាជាកន្លែងមានស្ថិរភាពនិងកំពុងមានសេដ្ឋកិច្ចលូតលាស់ជាមួយ "សេរីភាពទាំងអស់នៃសង្គមប្រជាធិបតេយ្យ រួមទាំងសេរីភាពខាងជំនឿសាសនា និង សេរីភាពនៃការបញ្ចេញមតិ"។ រហូតមកដល់ពេលនេះ មានតែបុគ្គលប្រាំមួយនាក់ប៉ុណ្ណោះដែលបានយល់ព្រមមកតាំងទីលំនៅជាថ្មីក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមអ្នកប្រាំមួយនាក់នោះ បួននាក់ (ម្នាក់ជាពួកមូស្លីមរ៉ូហ៊ីញយ៉ាពីប្រទេសភូមា និង បីនាក់ជាជនជាតិអ៊ីរ៉ង់) បានជ្រើសរើសធ្វើ

មាតុភូមិនិវត្តន៍ ដោយមិនគិតពីហានិភ័យនៃការធ្វើទុក្ខបុកម្នេញក្នុងប្រទេសកំណើតរបស់ពួកគេ។

ដូចនឹងសកម្មជននៃសង្គមស៊ីវិលផ្សេងទៀតដែរ ស្ថាប័នសាសនាក៏ប្រឈមនឹងបរិស្ថានដែលមានការគាបសង្កត់កាន់តែកើនឡើងផងដែរសម្រាប់ការចូលរួមពាក់ព័ន្ធជាសាធារណៈក្នុងប្រទេសកម្ពុជា។ ក្រមព្រហ្មទណ្ឌឆ្នាំ 2009 របស់កម្ពុជាបានហាមប្រាមការបរិហាកេរ្តិ៍ ដែលជាការអះអាងបំផ្លើសឬការទម្លាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយដែល "មានទំនោរនាំឲ្យប៉ះពាល់ដល់" កិត្តិយសឬកិត្តិសព្ទនៃបុគ្គលឬនៃស្ថាប័ន។ ការចោទប្រកាន់ពីបទបរិហាកេរ្តិ៍ត្រូវបានប្រើយ៉ាងទូលំទូលាយប្រឆាំងនឹងមេដឹកនាំបក្សប្រឆាំង ដែលជាការរារាំងដល់សេរីភាពក្នុងការបញ្ចេញមតិ។ ច្បាប់ស្តីពីសមាគមនិងអង្គការក្រៅរដ្ឋាភិបាល (LANGO) ឆ្នាំ 2015 បានផ្តល់ឆន្ទានុសិទ្ធិដល់ក្រសួងមហាផ្ទៃចំពោះការចុះបញ្ជីរបស់ក្រុមនិងការប្រមូលផ្តុំជាសាធារណៈ។ សិទ្ធិអំណាចនេះរួមបញ្ចូលនូវជម្រើសក្នុងការបដិសេធក្រុមមួយ ដោយផ្អែកលើការរក្សាសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សាធារណៈ ឯកភាពជាតិ វប្បធម៌ ប្រពៃណីនៃសង្គមកម្ពុជា។ អង្គការដែលបានចុះបញ្ជីត្រូវបានតម្រូវឲ្យគោរពតាមពាក្យដែលមានអត្ថន័យទូលំទូលាយគឺ "អព្យាក្រឹតភាពនយោបាយ"។ ជាពិសេស ព្រះសង្ឃពុទ្ធសាសនាក៏បានជួបប្រទះភាពលំបាកក្នុងការចុះឈ្មោះបោះឆ្នោត និង ទទួលអត្តសញ្ញាណបណ្ណអ្នកបោះឆ្នោតដែរ។ ដូចគ្នានេះដែរ ព្រះសង្ឃដែលពាក់ព័ន្ធក្នុងសកម្មភាពទាមទារសិទ្ធិលើដីធ្លី ត្រូវបានឃាត់ខ្លួន ហាមប្រាមមិនឲ្យចូលវត្ត និងត្រូវបានចាប់ផ្សឹកដោយព្រះសង្ឃជាន់ខ្ពស់នៃស្ថាប័នព្រះពុទ្ធសាសនាដែលមានសម្ពន្ធភាពជាមួយរដ្ឋាភិបាល។ ការវាយប្រហារលើសមាជិកសភាមកពីគណបក្សប្រឆាំងក្នុងខែឧសភា ឆ្នាំ 2016 និង ការធ្វើឃាតអ្នកវិភាគនយោបាយដ៏ល្បីល្បាញក្នុងខែកក្កដា ឆ្នាំ 2016 បានបង្កើននូវភាពភ័យខ្លាចក្នុងការបញ្ចេញមតិដោយសេរីនៅកម្ពុជា។